# ពិនិត្យមើលឲ្យប្រាកដ!

# ប្រាក់បៀវត្សអប្បរមា



ទាំងអ្នកធ្វើការងារ ទាំងអ្នកជួលបុគ្គលិកឲ្យធ្វើការងារ
កុំភ្លេចពិនិត្យមើល

## ទីក្រុងតូក្យូ ប្រាក់បៀវត្សអប្បបរមា

ចាប់ពីថ្ងៃទី 3
ខែតុលា ឆ្នាំ2025
នេះតទៅ
ចំនួនទឹកប្រាក់
ក្នុងមួយម៉ោង

**1,226 យ៉េន**

ធៀបនឹងឆ្នាំមុន UP
63 យ៉េន

カンボジア語版

ប្រាក់បៀវត្សអប្បបរមា គឺជាប្រព័ន្ធដែលធានា និងការពារនូវចំនួនទឹកប្រាក់អប្បបរមានៃប្រាក់បៀវត្សសម្រាប់បុគ្គលិកគ្រប់គ្នា។

ឆែកតាម WEB!
វេបសាយពិសេសដែលទាក់ទងនឹងប្រាក់បៀវត្សអប្បបរមា
(មានតែភាសាជប៉ុន)
最低賃金　特設サイト　検索

ពាក់ព័ន្ធនឹងប្រាក់បៀវត្សអប្បបរមា
សូមទាក់ទងមកមន្ទីរការងារតូក្យូ
ឬការិយាល័យត្រួតពិនិត្យ
ស្តង់ដារការងារនៅជិត
លោកអ្នកបំផុត។
東京労働局　検索

វេបសាយពិសេសអំពី
ការដំឡើងប្រាក់ឈ្នួល
(មានតែភាសាជប៉ុន)
មានផ្សព្វផ្សាយអំពីគោលនយោបាយ
គាំទ្រសម្រាប់ការដំឡើងប្រាក់ឈ្នួល។
賃金引上げ特設ページ　検索

ចំពោះលោក លោកស្រីដែលជា
ម្ចាស់ក្រុមហ៊ុនរកស៊ី
ខ្នាតតូច និងមធ្យម

業務改善
助成金
ជួយឧបត្ថម្ភយ៉ាងច្រើនបំផុត
ត្រឹម 600 ម៉ឺនយ៉េន



ក្រសួងសុខាភិបាល
ការងារនិងសុខុមាលភាព



# ទាំងអ្នកធ្វើការងារ ទាំងអ្នកជួលបុគ្គលិកឲ្យធ្វើការងារ។ ពិនិត្យមើលកុំខាន ប្រាក់បៀវត្សអប្បបរមា!

"ប្រព័ន្ធប្រាក់បៀវត្សអប្បបរមា" ត្រូវអនុវត្តចំពោះអ្នកធ្វើការងារទាំងអស់ ទោះបីមានអាយុ ឬរបៀបធ្វើការខុសគ្នាដូចជា ការងារមិនពេញម៉ោង ឬសិស្សនិស្សិតជាដើមក៏ដោយ។ សូមបំពេញប្រាក់បៀវត្សដែលចង់ឆែក(*1) និងចំនួនទឹកប្រាក់បៀវត្សអប្បបរមានៅរាជធានីខេត្តនៃកន្លែងធ្វើការ ចូលតារាងប្រៀបធៀប រួចប្រៀបធៀបវា!(*2)

## វិធីប្រៀបធៀបជាមួយចំនួនទឹកប្រាក់បៀវត្សអប្បបរមា

សូមសរសេរចូលនូវចំនួនទឹកប្រាក់បៀវត្សរបស់អ្នក និងចំនួនទឹកប្រាក់បៀវត្សអប្បបរមានៅរាជធានីខេត្តដែលត្រូវនឹងអ្នក។(*2)

**A អ្នកដែលមានប្រាក់ខែតាមម៉ោង**

| ប្រាក់ខែតាមម៉ោង | | ចំនួនទឹកប្រាក់បៀវត្សអប្បបរមា (ចំនួនទឹកប្រាក់ក្នុងមួយម៉ោង) |
|---|---|---|
| យ៉េន | ≥ | យ៉េន |

**B អ្នកដែលមានប្រាក់ខែតាមថ្ងៃ**

| ប្រាក់ខែតាមថ្ងៃ | | ចំនួនម៉ោងធ្វើការកំណត់ជាមធ្យមក្នុងមួយថ្ងៃ | | ចំនួនទឹកប្រាក់ក្នុងមួយម៉ោង | | ចំនួនទឹកប្រាក់បៀវត្សអប្បបរមា (ចំនួនទឹកប្រាក់ក្នុងមួយម៉ោង) |
|---|---|---|---|---|---|---|
| យ៉េន | ÷ | ម៉ោង | = | យ៉េន | ≥ | យ៉េន |

**C អ្នកដែលមានប្រាក់ខែតាមខែ**

| ប្រាក់ខែតាមខែ | | ចំនួនម៉ោងធ្វើការកំណត់ជាមធ្យមក្នុងមួយខែ | | ចំនួនទឹកប្រាក់ក្នុងមួយម៉ោង | | ចំនួនទឹកប្រាក់បៀវត្សអប្បបរមា (ចំនួនទឹកប្រាក់ក្នុងមួយម៉ោង) |
|---|---|---|---|---|---|---|
| យ៉េន | ÷ | ម៉ោង | = | យ៉េន | ≥ | យ៉េន |

**D អ្នកដែលរួមបញ្ចូលគ្នាចំណុច A B និង C ខាងលើ**

ឧទាហរណ៍ ក្នុងករណីដែលប្រាក់ខែគោល គឺប្រាក់ខែតាមថ្ងៃ ប៉ុន្តែប្រាក់បន្ថែមផ្សេងៗ (ដូចជាប្រាក់បន្ថែមនៅលើភារកិច្ច) ត្រូវបានបើកជូនជាប្រចាំខែ

① ប្រាក់ខែគោល (ប្រាក់ខែតាមថ្ងៃ) → គណនាចំនួនទឹកប្រាក់ក្នុងមួយម៉ោង តាមការគណនា B

② ប្រាក់បន្ថែមផ្សេងៗ (ប្រាក់ខែតាមខែ) → គណនាចំនួនទឹកប្រាក់ក្នុងមួយម៉ោង តាមការគណនា C

③ ចំនួនទឹកប្រាក់សរុបដែលបូក ① និង ② ≥ ចំនួនទឹកប្រាក់បៀវត្សអប្បបរមា (ចំនួនទឹកប្រាក់ក្នុងមួយម៉ោង)

(*1) ក្នុងការប្រៀបធៀបជាមួយចំនួនទឹកប្រាក់បៀវត្សអប្បបរមា មិនគិតរួមនូវប្រាក់បៀវត្សដូចតទៅ៖
① ប្រាក់បៀវត្សដែលទូទាត់បណ្ដោះអាសន្ន (ដូចជាប្រាក់ឧបត្ថម្ភសម្រាប់ការរៀបអាពាហ៍ពិពាហ៍) ② ប្រាក់បៀវត្សដែលទូទាត់រាល់រយៈពេលដែលលើស១ខែ (ដូចជាប្រាក់រង្វាន់លើកទឹកចិត្ត) ③ ប្រាក់បៀវត្សដែលទូទាត់សម្រាប់ម៉ោងធ្វើការដែលហួសពីម៉ោងការងារដែលកំណត់ (ដូចជាប្រាក់បៀវត្សបន្ថែមទៅលើការងារថែមម៉ោង) ④ ប្រាក់បៀវត្សដែលទូទាត់សម្រាប់ម៉ោងធ្វើការក្នុងថ្ងៃដែលមិនមែនជាថ្ងៃការងារដែលកំណត់ (ដូចជាប្រាក់បៀវត្សបន្ថែមលើការងារនៅថ្ងៃឈប់សម្រាក) ⑤ ចំនួនលើសពីចំនួនទឹកប្រាក់ដែលគណនាប្រាក់បៀវត្សតាមម៉ោងការងារធម្មតា ក្នុងប្រាក់បៀវត្សដែលទូទាត់ចំពោះការងារក្នុងរយៈពេលចាប់ពីម៉ោង១០យប់ រហូតដល់ម៉ោង៥ព្រឹក (ដូចជាប្រាក់បៀវត្សបន្ថែមលើការងារពេលយប់) ⑥ ប្រាក់បន្ថែមសម្រាប់ការវត្តមានមិនឈប់សោះ ប្រាក់បន្ថែមសម្រាប់ការធ្វើដំណើរ និងប្រាក់ឧបត្ថម្ភសម្រាប់គ្រួសារ
(*2) វិធីគណនាលម្អិត និងវិធីគណនាក្នុងករណីប្រាក់ខែតាមលទ្ធភាពស្នាដៃ សូមទាក់ទងមកមន្ទីរការងារឬការិយាល័យត្រួតពិនិត្យស្តង់ដារការងារនៅជិតលោកអ្នកបំផុត

## 業務改善助成金

ជួយឧបត្ថម្ភយ៉ាងច្រើនបំផុត ត្រឹម 600 ម៉ឺនយ៉េន

## លោក លោកស្រីដែលជាម្ចាស់ក្រុមហ៊ុនរកស៊ីខ្នាតតូច និងមធ្យម

តោះនាំគ្នាប្រើ "ប្រាក់ឧបត្ថម្ភលើកកម្ពស់ផ្នែកធុរកិច្ច" ដែលគាំទ្រការដំឡើងប្រាក់បៀវត្ស!



### អ្វីទៅជា "ប្រាក់ឧបត្ថម្ភលើកកម្ពស់ផ្នែកធុរកិច្ច" ?

"ប្រាក់ឧបត្ថម្ភលើកកម្ពស់ផ្នែកធុរកិច្ច" គឺជាប្រាក់ឧបត្ថម្ភដែលផ្តល់ជំនួយដល់សហគ្រាសតូចនិងមធ្យម និងប្រតិបត្តិករអាជីវកម្មខ្នាតតូច ដែលមានគោលដៅបង្កើនផលិតភាពនិងដំឡើង "ប្រាក់បៀវត្សទាបបំផុតនៅក្នុងកន្លែងធ្វើអាជីវកម្ម (ប្រាក់បៀវត្សអប្បបរមាក្នុងកន្លែងធ្វើអាជីវកម្ម)"។ ក្នុងករណីដែលបានធ្វើការវិនិយោគលើសម្ភារៈជាដើម យើងនឹងឧបត្ថម្ភមួយផ្នែកនៃចំណាយនោះអាស្រ័យតាមលក្ខខណ្ឌចាំបាច់ត្រូវផ្តល់ឲ្យ។

**មជ្ឈមណ្ឌលផ្តល់ព័ត៌មានតាមទូរសព្ទ អំពីប្រាក់ឧបត្ថម្ភលើកកម្ពស់ផ្នែកធុរកិច្ច**

0120-366-440

**ព័ត៌មានលម្អិតសូមឆែកមើលនៅទីនេះ (មានតែភាសាជប៉ុន)**

業務改善助成金 検索

### លក្ខខណ្ឌចាំបាច់ត្រូវផ្តល់ឲ្យ

- ដំឡើងប្រាក់បៀវត្សអប្បបរមាក្នុងកន្លែងធ្វើអាជីវកម្ម
- ទូទាត់ប្រាក់បៀវត្សក្រោយដំឡើង
- ដាក់បញ្ចូលម៉ាស៊ីនឧបករណ៍និងសម្ភារៈជាដើមដើម្បីបង្កើនផលិតភាព
- គ្មានមូលហេតុនៃការមិនផ្តល់ការឧបត្ថម្ភ ដូចជាការបញ្ឈប់ពីការងារ ការបញ្ចុះប្រាក់បៀវត្សជាដើម

ឧបត្ថម្ភមួយផ្នែកនៃចំណាយចាំបាច់សម្រាប់ការវិនិយោគលើសម្ភារៈជាដើម

ពិនិត្យមើលទិដ្ឋភាពទូទៅតាមវីដេអូ!

### ជំហានរហូតដល់ការផ្តល់ប្រាក់ឧបត្ថម្ភ

1. ដាក់ពាក្យស្នើសុំប្រាក់ឧបត្ថម្ភ និងផែនការអនុវត្តគម្រោងជាដើម ទៅមន្ទីរការងារនៃរាជធានីខេត្ត ដែលកន្លែងធ្វើអាជីវកម្មស្ថិតនៅ

ត្រួតពិនិត្យ

2. ក្រោយសម្រេចផ្តល់ប្រាក់ឧបត្ថម្ភ អនុវត្តគម្រោងតាមផែនការ ដែលបានដាក់ពាក្យមក
3. ដាក់របាយការណ៍លទ្ធផលនៃការអនុវត្ត និងពាក្យស្នើសុំផ្តល់ប្រាក់ឧបត្ថម្ភ ទៅមន្ទីរការងារ

ត្រួតពិនិត្យ

4. ផ្តល់ឲ្យ

ពិនិត្យមើលបែបបទតាមវីដេអូ!

### ផ្តល់ការប្រឹក្សាដោយឥតគិតថ្លៃជាមួយអ្នកជំនាញ

អ្នកដែលមានកង្វល់អំពីការដំឡើងប្រាក់បៀវត្ស សូមប្រឹក្សាជាមួយមជ្ឈមណ្ឌលគាំទ្រលើកកម្ពស់កំណែទម្រង់របៀបធ្វើការ។

ព័ត៌មានលម្អិតសូមឆែកមើលនៅទីនេះ (មានតែភាសាជប៉ុន) 働き方改革推進支援センター 検索

### មូលនិធិគាំទ្រកំណែទម្រង់របៀបធ្វើការ

សាជីវកម្មហិរញ្ញវត្ថុនយោបាយជប៉ុន កំពុងផ្តល់ហិរញ្ញប្បទានសម្រាប់បរិក្ខារនិងប្រតិបត្តិការ ទៅកាន់និយោជកដែលខិតខំប្រឹងប្រែងដំឡើងប្រាក់បៀវត្សអប្បបរមានៅក្នុងកន្លែងធ្វើអាជីវកម្ម។

ព័ត៌មានលម្អិតសូមឆែកមើលនៅទីនេះ (មានតែភាសាជប៉ុន) 働き方改革推進支援資金 検索

リサイクル適性Ⓐ
この印刷物は、印刷用の紙へリサイクルできます。

(R7.9)